**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០២...សរ

# សារាចរ

## ស្តីពី

## ការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចង្កូតស្តាំ ដែលមានស្រាប់នៅក្នុងប្រទេស

---

ប៉ុន្មានឆ្នាំចុងក្រោយនេះ បន្ទាប់ពីការខិតខំប្រឹងប្រែងស្តាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅទូទាំងប្រទេសរួចមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា ចំនួនយានយន្តគ្រប់ប្រភេទបានកើនឡើងឥតឈប់ឈរ ដែលបង្កឱ្យមានការកកស្ទះ ការបាត់សណ្តាប់ធ្នាប់សាធារណៈ និងគ្រោះថ្នាក់ចរាចរជាញឹកញាប់នៅតាមដងផ្លូវ។ គ្រោះថ្នាក់ចរាចរនេះ មួយផ្នែកបង្កឡើងដោយអ្នកបើកបររថយន្តចង្កូតស្តាំដែលគ្មានផ្លាកលេខ ពាក់ផ្លាកលេខក្លែងក្លាយ និងគ្មានការបង់ពន្ធនាំចូល ហើយបើកបរគេចពីសមត្ថកិច្ចត្រួតពិនិត្យតាមដងផ្លូវ ដែលបានបង្កឡើងនូវបទឧក្រិដ្ឋ បទល្មើសចរាចរ និងធ្វើឱ្យបាត់បង់ចំណូលថវិការដ្ឋ ។

ដើម្បីកែលំអនូវបាតុភាពអសកម្មខាងលើ បង្កើនការគ្រប់គ្រងយានយន្តគ្រប់ប្រភេទឱ្យបានកាន់តែល្អប្រសើរ និងការបង្កើនចំណូលថវិការដ្ឋ រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅ :

១- អនុញ្ញាតឱ្យរថយន្តចង្កូតស្តាំគ្រប់ប្រភេទ ដែលបាននាំចូលកន្លងមកទាំងអស់ មានសិទ្ធិធ្វើចរាចរដោយស្របច្បាប់លើផ្លូវសាធារណៈ ដោយត្រូវបំពេញកាតព្វកិច្ចបង់ពន្ធ និងធ្វើផ្លាកលេខឱ្យបានត្រឹមត្រូវចាប់ពីពេលនេះតទៅ។

២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវរៀបចំជាបន្ទាន់នូវប្រកាសរួមអន្តរក្រសួង ដើម្បីណែនាំដល់ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ ឱ្យមានវិធានការម៉ឺងម៉ាត់ដល់ម្ចាស់រថយន្តចង្កូតស្តាំទាំងអស់ ឱ្យបំពេញកាតព្វកិច្ចបង់ពន្ធឱ្យបានត្រឹមត្រូវ និងសមស្របតាមប្រភេទ និងគុណភាពរថយន្ត និងធ្វើការណែនាំដល់អគ្គនាយកដ្ឋានដឹកជញ្ជូនឱ្យផ្តល់ប័ណ្ណសំគាល់ និងផ្លាកលេខរថយន្តចង្កូតស្តាំ ដែលបានបំពេញកាតព្វកិច្ចបង់ពន្ធរួចហើយឱ្យបានឆាប់

របស់ រួចបញ្ជូនបញ្ជីរថយន្តទាំងនោះ ទៅអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃដើម្បីគ្រប់គ្រងបន្ត។

៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវធ្វើការណែនាំជាបន្ទាន់ដល់មន្ត្រីមានសមត្ថកិច្ច ដែលបំពេញការងារនៅតាមច្រកទ្វារព្រំដែនទាំងអស់ ត្រូវទប់ស្កាត់ និងបញ្ឈប់មិនឱ្យមានការនាំចូលជាដាច់ខាតនូវរថយន្តចង្កូតស្តាំគ្រប់ប្រភេទជាបន្តទៀត ចាប់ពីពេលនេះតទៅ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងអាជ្ញាធរដែនដីពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្ត ឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឯកសារ កាលប្បវត្តិ